ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 31

# ភាគកម្មក្នុងក្រុមហ៊ុនរួមទុន

## Interests in Joint Ventures

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ

International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**



បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៙

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឋិ តាឃី**

១ ស្តង់ដានេះត្រូវបានប្រើនៅក្នុងការធ្វើគណនេយ្យកម្មសម្រាប់ភាគកម្ម នៅក្នុងក្រុមហ៊ុនរួមទុន និងការរាយការណ៍ពីទ្រព្យសកម្ម បំណុលចំណូល និងចំណាយរបស់ក្រុមហ៊ុនរួមទុននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភាគីរួមទុន និងអ្នកវិនិយោគ ដោយមិនគិតពីរចនាសម្ព័ន្ធ ឬទម្រង់ដែលសកម្មភាពរបស់ក្រុមហ៊ុនរួមទុនកើតឡើងនោះទេ។ ប៉ុន្តែ ស្តង់ដានេះមិនអនុវត្តចំពោះ ភាគកម្មរបស់ភាគីរួមទុន នៅក្នុងអង្គភាពគ្រប់គ្រងរួមដែលកាន់កាប់ដោយៈ

(ក) ការរៀបចំដើមទុនរួម ឬ

(ខ) មូលនិធិ អង្គភាពបរធន និងអង្គភាពស្រដៀងគ្នា ដោយរួម បញ្ចូលទាំងមូលនិធិធានារ៉ាប់រង ដែលជាប់នឹងការវិនិយោគ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របតាមរយៈរបាយការណ៍ ចំណេញឬខាតដោយអនុលោមតាម ស.រ.ហ.អ.ក ៩ *ឧបករណ៍ ហិរញ្ញវត្ថុ* ។ ភាគីរួមទុនដែលកាន់កាប់ភាគកម្មនេះ ត្រូវធ្វើការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ៥៥ និង ៥៦ ។

២ ភាគីរួមទុនដែលមានភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួមត្រូវបានលើកលែងពីកថាខណ្ឌ ៣០ (ការបង្រួមតាមសមាមាត្រ ) និង ៣៨ (វិធីសាស្ត្រ មូលធន) នៅពេលដែលភាគកម្មបំពេញលក្ខខណ្ឌ ដូចខាងក្រោមៈ

(ក) ភាគកម្មត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ដោយ

អនុលោម តាម ស.រ.ហ.អ.ក ៥ *ទ្រព្យសកម្ម រយៈពេលវែងដែលរក្សាទុកសម្រាប់លក់ និង កិច្ចប្រតិបត្តិការមិនបន្ត*

(ខ) ការលើកលែងនៅក្នុងកថាខណ្ឌ ១០ នៃ ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក និងរបាយការណ៍ហិរញ្ញវត្ថុរួម* ដែលអនុញ្ញាតឱ្យក្រុមហ៊ុនមេ ដែលមានភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួម មិនបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលអាចអនុវត្តបាន ឬ

(គ) ចំណុចទាំងអស់ខាងក្រោមនេះអនុវត្តៈ

(១) ភាគីរួមទុនគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ទាំងស្រុង ឬជាក្រុមហ៊ុនបុត្រសម្ព័ន្ធ កាន់កាប់មួយផ្នែកនៃ អង្គភាពមួយផ្សេងទៀត និងម្ចាស់របស់អង្គភាពរួម បញ្ចូលទាំងម្ចាស់ដែលមិនមែនសិទ្ធិបោះឆ្នោត ត្រូវបានគេប្រាប់ឱ្យដឹងពីនិងមិនជំទាស់ទៅនឹងភាគីរួមទុន ដែលមិនអនុវត្តការបង្រួមតាមសមាមាត្រឬវិធីសាស្ត្រមូលធន

(២) ឧបករណ៍មូលធន និងបំណុលរបស់ភាគីរួមទុនមិនត្រូវបានជួញដូរនៅក្នុងទីផ្សារសាធារណៈទេ (ទីផ្សារហ៊ុនក្នុងស្រុកនិងបរទេស ឬទីផ្សារតាមបញ្ជរ រួមបញ្ចូលទាំងទីផ្សារតំបន់និងក្នុងស្រុកផង)

(៣) ភាគីរួមទុនមិនដាក់ឯកសារ និងមិននៅក្នុងដំណើរការ នៃការដាក់ឯកសាររបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ជាមួយគណៈកម្មការមូលបត្រ ឬ ស្ថាប័នច្បាប់ផ្សេងទៀត

សម្រាប់គោលបំណងនៃការបោះផ្សាយលក់ថ្នាក់ណាមួយនៃឧបករណ៍នៅក្នុងទីផ្សារសាធារណៈ និង

(៨) ក្រុមហ៊ុនមេចុងក្រោយបង្អស់ ឬក្រុមហ៊ុនមេថ្នាក់មធ្យមនៃភាគីរួមទុនផលិតរបាយការណ៍ហិរញ្ញវត្ថុរួម ឱ្យមានសម្រាប់ការប្រើប្រាស់ជាសាធារណៈដែលអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ។

## និយមន័យ

៣ វាក្យសព្ទខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងអត្ថន័យ ដូចមានបញ្ជាក់ដូចខាងក្រោមៈ

*គ្រប់គ្រង* គឺជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុនិងកិច្ចប្រតិបត្តិការនៃសកម្មភាពសេដ្ឋកិច្ចដើម្បីទទួលបានអត្ថប្រយោជន៍ពីអំណាចនោះ។

*វិធីសាស្រ្តមូលធន* គឺជាវិធីសាស្រ្តគណនេយ្យដែលភាគកម្មនៅក្នុងអង្គភាពរួមទុនត្រូវបានកត់ត្រាលើកដំបូង តាមថ្លៃដើមហើយត្រូវបានកែសម្រួល នៅពេលបន្ទាប់សម្រាប់ការប្រែប្រួលក្រោយការទិញនៅក្នុងចំណែករបស់ ភាគីរួម ទុននៃទ្រព្យសកម្មពិតនៃអង្គភាពគ្រប់គ្រងរួម។ របាយការណ៍ចំណេញ ឬខាតរបស់ភាគីរួមទុនរួមបញ្ចូលទាំងចំណែករបស់ភាគីរួមទុននៃប្រាក់ចំណេញ ឬខាតនៃអង្គភាពគ្រប់គ្រងរួម។

*អ្នកវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន* គឺជាភាគីមួយចំពោះក្រុមហ៊ុនរួមទុន

និងមិនមានការគ្រប់គ្រងរួមលើ ក្រុមហ៊ុនរួមទុននោះទេ។

*ការគ្រប់គ្រងរួម* គឺជាចំណែកនៃការគ្រប់គ្រងដែលបានព្រមព្រៀងគ្នាតាមកិច្ចសន្យាលើសកម្មភាពសេដ្ឋកិច្ច និងកើតឡើងតែនៅពេលដែលការសំរេចចិត្តផ្នែកហិរញ្ញវត្ថុនិងកិច្ចប្រតិបត្តិការជាយុទ្ធសាស្ត្រដែលទាក់ ទិននឹងសកម្មភាពបានតម្រូវឱ្យមានការយល់ព្រមជាឯកច្ឆ័ន្ទពីភាគីទាំងអស់ដែលមានចំណែកគ្រប់គ្រង (ភាគីរួមទុន)។

*ក្រុមហ៊ុនរួមទុន* គឺជាការរៀបចំតាមកិច្ចព្រមព្រៀងមួយដែលភាគីពីរ ឬច្រើនអនុវត្តសកម្មភាពសេដ្ឋកិច្ច ដែលជាកម្មវត្ថុនៃការគ្រប់គ្រងរួម។

*ការបង្រួមតាមសមាមាត្រ* គឺជាវិធីសាស្ត្រគណនេយ្យមួយដែលចំណែករបស់ភាគីរួមទុននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនីមួយៗ នៃអង្គភាពគ្រប់គ្រងរួមត្រូវបានបញ្ចូលគ្នាតាមបន្ទាត់គណនី ម្តងមួយៗ ជាមួយធាតុស្រដៀងគ្នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភាគីរួមទុន ឬ ត្រូវបានរាយការណ៍ជាធាតុ ដែលមានបន្ទាប់គណនីដាច់ដោយឡែកនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភាគីរួមទុន។

*របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក* គឺជារបាយការណ៍ទាំងឡាយ ដែលបានដាក់បង្ហាញដោយក្រុមហ៊ុនមេ ដែលជាអ្នកវិនិយោគមួយនៅក្នុង សមាគត ឬ នៅក្នុងភាគីរួមទុននៅក្នុងអង្គភាពគ្រប់គ្រងរួម ដែលការវិនិយោគត្រូវបានធ្វើគណនេយ្យកម្មតាមមូលដ្ឋាននៃភាគកម្មមូលធនផ្ទាល់ជាជាងតាមមូលដ្ឋាននៃលទ្ធផលដែលបានរាយការណ៍រួច និងទ្រព្យសកម្ម ពិតរបស់ក្រុមហ៊ុនរងការវិនិយោគ។

*ឥទ្ធិពលសំខាន់* គឺជាអំណាចដើម្បីចូលរួមនៅក្នុងការសំរេចចិត្តគោល

**នយោបាយផ្នែកហិរញ្ញវត្ថុនិងផ្នែក កិច្ចប្រតិបត្តិការនៃសកម្មភាពសេដ្ឋកិច្ច ប៉ុន្តែមិនមែនជាការការគ្រប់គ្រង ឬការគ្រប់គ្រងរួមលើគោលនយោបាយទាំងនោះទេ។**

*ភាគីរួមទុន* **គឺជាភាគីមួយចំពោះក្រុមហ៊ុនរួមទុន និងមានការគ្រប់គ្រង រួមលើក្រុមហ៊ុនរួមទុននោះ។**

៤ របាយការណ៍ហិរញ្ញវត្ថុដែលការបង្រួមតាមសមាមាត្រ ឬវិធីសាស្ត្រមូលធនត្រូវបានប្រើ គឺមិនមែនជារបាយ ការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកទេ និងក៏មិនមែនជារបាយការណ៍ហិរញ្ញវត្ថុ នៃអង្គភាពមួយដែលមិនមានក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ភាគកម្មរបស់ភាគីរួមទុននៅក្នុងអង្គភាពគ្រប់គ្រងរួម ។

៥ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកគឺជារបាយការណ៍ ដែលបានដាក់បង្ហាញបន្ថែមលើរបាយការណ៍ហិរញ្ញវត្ថុរួម របាយការណ៍ហិរញ្ញវត្ថុ ដែលការវិនិយោគត្រូវបានធ្វើគណនេយ្យកម្មដោយប្រើវិធីសាស្ត្រមូលធន និងរបាយការណ៍ហិរញ្ញវត្ថុដែលភាគកម្មរបស់ភាគីរួមទុន នៅក្នុងក្រុមហ៊ុនរួមទុនត្រូវបានបង្រួមតាមសមាមាត្រ។ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកមិនចាំបាច់ត្រូវបន្ថែមចំពោះ ឬអមជាមួយរបាយការណ៍ ទាំងនោះទេ ។

៦ អង្គភាពទាំងឡាយដែលត្រូវបានលើកលែងដោយអនុលោមតាមកថាខណ្ឌ ១០ នៃ ស.គ.អ.ក ២៧ ពីការ បង្រួម កថាខណ្ឌ១៣(គ) នៃ ស.គ.អ ២៨ *ការវិនិយោគនៅក្នុងសមាគត* ពីការប្រើវិធីសាស្ត្រមូលធន ឬ កថាខណ្ឌ ២ នៃស្តង់ដានេះពីការអនុវត្តការបង្រួមតាមសមាមាត្រឬវិធីសាស្ត្រមូលធន អាចដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ជារបាយការណ៍ហិរញ្ញវត្ថុរបស់គេតែមួយគត់ ។

## ទម្រង់នៃក្រុមហ៊ុនរួមទុន

៧ ក្រុមហ៊ុនរួមទុនអាចមានទម្រង់និងរចនាសម្ព័ន្ធច្រើនខុសៗគ្នា ។ ស្តង់ដានេះកំណត់អត្តសញ្ញាណបីប្រភេទធំៗ កិច្ចប្រតិបត្តិការគ្រប់គ្រងរួម ទ្រព្យសកម្មគ្រប់គ្រងរួម និងអង្គភាពគ្រប់គ្រងរួម-ដែលជាទូទៅត្រូវបាន ចាត់ទុកជា និងបំពេញនិយមន័យជា ក្រុមហ៊ុនរួមទុន។ ចរិតលក្ខណៈខាងក្រោម គឺជាលក្ខណៈទូទៅចំពោះ ក្រុមហ៊ុនរួមទុនទាំងអស់ៈ

(ក) ភាគីរួមទុនពីរឬច្រើនត្រូវបានចងដោយកិច្ចសន្យា និង

(ខ) កិច្ចសន្យាបង្កើតបានការគ្រប់គ្រងរួម។

## ការគ្រប់គ្រងរួម

៨ ការគ្រប់គ្រងរួម អាចត្រូវបានច្រានចោល នៅពេលដែលអង្គភាពរងការវិនិយោគគឺស្ថិតនៅក្នុងការរៀបចំឡើងវិញ ឬនៅក្នុងភាពក្ស័យធន ឬធ្វើកិច្ចប្រតិបត្តិក្រោមការហាមឃាត់រយៈពេលដ៏ធ្ងន់ធ្ងរទៅលើលទ្ធភាព របស់ក្រុមហ៊ុនដើម្បីផ្ទេរមូលនិធិទៅឱ្យភាគីរួមទុន ។ ប្រសិនបើការគ្រប់គ្រងរួមកំពុងបន្ត ព្រឹត្តិការណ៍ទាំងនេះមិន គ្រប់គ្រាន់ចំពោះខ្លួនឯងដើម្បីធ្វើឱ្យត្រូវមិនមែនធ្វើគណនេយ្យកម្មក្រុមហ៊ុនរួមទុន ដោយអនុលោមតាមស្តង់ដានេះ។

## ការរៀបចំកិច្ចព្រមព្រៀង

៩ ការកើតមាននៃកិច្ចព្រមព្រៀងញែកចេញនូវភាគកម្មដែលទាក់ទិននឹងការគ្រប់គ្រងរួមពីការវិនិយោគនៅក្នុង សមាគតដែលអ្នកវិនិយោគមានឥទ្ធិពល

សំខាន់ (សូមមើល ស.គ.អ.ក ២៨)។ សកម្មភាពដែលមិនមាន ការរៀបចំដើម្បីបង្កើតការគ្រប់គ្រងរួម គឺមិនមែនជាក្រុមហ៊ុនរួមទុន សម្រាប់គោលបំណងនៃស្តង់ដានេះទេ។

១០ ការរៀបចំកិច្ចព្រមព្រៀង អាចត្រូវបានផ្តល់ភស្តុតាង តាមរបៀបច្រើនយ៉ាង ជាឧទាហរណ៍ ដោយកិច្ចសន្យារវាងភាគីរួមទុន ឬ កំណត់ហេតុនៃការពិភាក្សារវាងភាគីរួមទុន ។ នៅក្នុងករណីខ្លះ ការរៀបចំត្រូវបានគេបញ្ចូលទៅក្នុងប្រការ ឬបទបញ្ជាផ្ទៃក្នុងផ្សេងទៀត នៃក្រុមហ៊ុនរួមទុន។ ទោះបីជាក្នុងទម្រង់ណាក៏ដោយ ក៏ការរៀបចំកិច្ចសន្យា ជាធម្មតាត្រូវបានសរសេរជាលាយលក្ខអក្សរ និងដោយស្រាយនូវបញ្ហាទាំងនេះ ជាៈ

(ក) សកម្មភាព កំឡុងពេល និងកាតព្វកិច្ចរាយការណ៍នៃក្រុមហ៊ុន រួមទុន។

(ខ) ការតែងតាំងក្រុមប្រឹក្សានាយក ឬស្ថាប័នគ្រប់គ្រងសមមូល នៃក្រុមហ៊ុនរួមទុន និងសិទ្ធិបោះឆ្នោត របស់ភាគីរួមទុន

(គ) ការដាក់មូលធនវិនិយោគដោយភាគីរួមទុន និង

(ឃ) ការបែងចែកចំណែកដោយភាគីរួមទុននៃទិន្នផលចំណូលចំណាយ ឬលទ្ធផលនៃក្រុមហ៊ុនរួមទុន។

១១ ការរៀបចំកិច្ចសន្យាបង្កើតឡើង នូវការគ្រប់គ្រងរួមលើក្រុមហ៊ុនរួមទុន ។ ការតម្រូវបែបនេះធានាថា មិនមានភាគីរួមទុនតែមួយស្ថិតនៅក្នុងស្ថានភាពគ្រប់គ្រងសកម្មភាពឯកតោភាគីនោះទេ ។

១២ ការរៀបចំកិច្ចសន្យាអាចកំណត់អត្តសញ្ញាណភាគីរួមទុនមួយជាប្រតិបត្តិករ ឬជាអ្នកគ្រប់គ្រងនៃក្រុមហ៊ុនរួមទុន ។ ប្រតិបត្តិការមិនគ្រប់គ្រងក្រុមហ៊ុន

រួមទុនទេ ប៉ុន្តែធ្វើសកម្មភាពនៅក្នុងគោលនយោបាយផ្នែកហិរញ្ញវត្ថុ និង ផ្នែកកិច្ចប្រតិបត្តិការ ដែលត្រូវបានយល់ព្រមដោយភាគីរួមទុន ដោយ អនុលោមតាមការរៀបចំកិច្ចព្រមព្រៀង និងត្រូវបានផ្ទេរអំណាចទៅឱ្យ ប្រតិបត្តិករ ។ ប្រសិនបើ ប្រតិបត្តិករមានអំណាច ដើម្បីគ្រប់គ្រងគោល នយោបាយផ្នែកហិរញ្ញវត្ថុ និងផ្នែកកិច្ចប្រតិបត្តិការនៃសកម្មភាពសេដ្ឋកិច្ច ប្រតិបត្តិករនោះគ្រប់គ្រង ហើយក្រុមហ៊ុនរួមទុនគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃប្រតិបត្តិករ និងមិនមែនជាក្រុមហ៊ុនរួមទុនទេ ។

កិច្ចប្រតិបត្តិការគ្រប់គ្រងរួម

១៣ កិច្ចប្រតិបត្តិការនៃក្រុមហ៊ុនរួមទុនមួយចំនួន ពាក់ព័ន្ធនឹងការប្រើប្រាស់ ទ្រព្យសកម្ម និងធនធានផ្សេងទៀតរបស់ភាគីរួមទុន ជាជាងការបង្កើត សារជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ អង្គភាពផ្សេងទៀត ឬ រចនាសម្ព័ន្ធ ហិរញ្ញវត្ថុដែលដាច់ដោយឡែកពីភាគីរួមទុនខ្លួនគេ ។ ភាគីរួមទុនប្រើប្រាស់ ទ្រព្យ រោងចក្រ និងបរិក្ខារផ្ទាល់ ខ្លួនរបស់គេ និងកត់ត្រាសន្និធិផ្ទាល់ខ្លួន របស់គេ ។ វាក៏កើតឡើងផងដែរនូវចំណាយនិងបំណុលផ្ទាល់ខ្លួន និង គៀងគរហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់គេ ដែលតំណាងឱ្យកាតព្វកិច្ចផ្ទាល់ខ្លួន របស់គេ ។ សកម្មភាពក្រុមហ៊ុនរួមទុន អាចត្រូវបានអនុវត្តដោយនិយោជិក របស់ភាគីរួមទុន អមជាមួយនឹងសកម្មភាពរបស់ភាគីរួមទុន ។ កិច្ចព្រម ព្រៀង របស់ក្រុមហ៊ុនរួមទុនជាទូទៅផ្តល់មធ្យោបាយដែលផលរបរពីការ លក់ទំនិញនៃផលិតផលរួម និងចំណាយរួមណាមួយ ដែលបានកើតឡើង ជារួមត្រូវបានចែករំលែកក្នុងចំណោមភាគីរួមទុន។

១៤ ឧទាហរណ៍នៃកិច្ចប្រតិបត្តិការរួមទុនគឺនៅពេលដែលភាគីរួមទុនពីរ ឬច្រើន

បញ្ចូលគ្នានូវកិច្ចប្រតិបត្តិការ ធនធាន និងជំនាញដើម្បីផលិត ដើម្បីដាក់លក់ផលិតផលនៅទីផ្សារ និងចែកចាយផលិតផលជាក់លាក់ រួមគ្នា ដូចជាយន្តហោះជាដើម ។ ផ្នែកខុសៗគ្នានៃដំណើរផលិតត្រូវបានអនុវត្ត ដោយភាគីរួមទុននីមួយៗ។ ភាគីរួមទុននីមួយៗរ៉ាប់រងថ្លៃដើមផ្ទាល់ខ្លួន និងទទួលបានចំណែក នៃផលរបរពីការលក់យន្តហោះ ចំណែកបែបនេះត្រូវបានកំណត់ដោយអនុលោមតាមការរៀបចំកិច្ចព្រមព្រៀង ។

១៥ **ទាក់ទិននឹងភាគកម្មនៅក្នុងកិច្ចប្រតិបត្តិការគ្រប់គ្រងរួម ភាគីរួមទុនត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុៈ**

**(ក) នូវទ្រព្យសកម្មដែលភាគីរួមទុនគ្រប់គ្រង និងបំណុលដែលភាគីរួមទុនកើតមានឡើង និង**

**(ខ) ចំណាយដែលភាគីរួមទុនកើតមានឡើង និងចំណែកនៃប្រាក់ចំណេញរបស់ខ្លួនដែលខ្លួនរកបានពី ការលក់ទំនិញ ឬសេវាដោយក្រុមហ៊ុនរួមទុន។**

១៦ ពីព្រោះតែទ្រព្យសកម្ម បំណុល ចំណូល និងចំណាយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ភាគីរួមទុន ដូច្នេះពុំមានការកែសម្រួល ឬ នីតិវិធីបង្រួមផ្សេងទៀត ត្រូវបានតម្រូវឱ្យមានទេទាក់ទិននឹងធាតុទាំងនេះ នៅពេលដែលភាគីរួមទុនដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ។

១៧ ឯកសារគណនេយ្យដាច់ដោយឡែក មិនអាចត្រូវបានតម្រូវឱ្យមានទេសម្រាប់ក្រុមហ៊ុនរួមទុនខ្លួនឯង និងរបាយការណ៍ហិរញ្ញវត្ថុមិនអាចត្រូវបានរៀបចំសម្រាប់ក្រុមហ៊ុនរួមទុន ។ ប៉ុន្តែភាគីរួមទុនអាចរៀបចំគណនីគ្រប់គ្រង ដូច្នេះភាគីរួមទុនអាចវាយតម្លៃពីលទ្ធផលនៃក្រុមហ៊ុនទុនបាន ។

១៨ ក្រុមហ៊ុនរួមទុនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរួម និងជារឿយៗ ការកាន់កាប់រួម ដោយភាគីរួមទុននៃទ្រព្យសកម្មមួយ ឬច្រើន ដែលបានដាក់ទុនទៅក្នុង ឬ បានទិញសម្រាប់គោលបំណងនៃ ក្រុមហ៊ុនរួមទុន និងមានគោលបំណងពិសេសនៃក្រុមហ៊ុនរួមទុន ។ ទ្រព្យសកម្មត្រូវបានប្រើ ដើម្បីទទួល បានអត្ថប្រយោជន៍សម្រាប់ភាគីរួមទុន ។ ភាគីរួមទុនអាចចែកចំណែកនៃ ទិន្នផលពីទ្រព្យសកម្ម និងភាគីនីមួយៗ រ៉ាប់រងលើចំណែកចំណាយបាន ព្រមព្រៀងគ្នាដែលបានកើតឡើង ។

១៩ ក្រុមហ៊ុនរួមទុនទាំងនេះ មិនពាក់ព័ន្ធនឹងការបង្កើតសារជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងទៀត ឬរចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលដាច់ដោយឡែកពីភាគីរួមទុនខ្លួនគេ ។ ភាគីរួមទុនមានការគ្រប់គ្រងរួមលើចំណែករបស់ខ្លួននៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត តាមរយៈចំណែករបស់ខ្លួននៃទ្រព្យសកម្មគ្រប់គ្រងរួម។

២០ សកម្មភាពជាច្រើននៅក្នុងឧស្សាហកម្មរ៉ែ ឧស្ម័ន និងប្រេង ជាប់ទាក់ទងនឹងទ្រព្យសកម្មគ្រប់គ្រងរួម។ ឧទាហរណ៍ ក្រុមហ៊ុនផលិតប្រេងមួយចំនួនអាចគ្រប់គ្រង និងធ្វើកិច្ចប្រតិបត្តិការរួមទៅលើបំពង់បង្ហូរប្រេង ។ ភាគីរួមទុនប្រើបំពង់បង្ហូរប្រេងដើម្បីដឹកជញ្ជូនផលិតផលរបស់ខ្លួននៅក្នុងចំណូលដែលក្រុមហ៊ុនរ៉ាប់រងចំណែកចំណាយបានព្រមព្រៀងរួចនៃកិច្ចប្រតិបត្តិការបំពង់បង្ហូរប្រេង។ ឧទាហរណ៍មួយទៀតនៃទ្រព្យសកម្មគ្រប់គ្រងរួម គឺនៅពេលដែលអង្គភាពពីរគ្រប់គ្រងរួមគ្នាលើទ្រព្យ ដែលអង្គភាពនីមួយៗទទួលបានចំណែកនៃការជួលដែលបានទទួល និងរ៉ាប់រងចំណែកនៃចំណាយ ។

**២១ ទាក់ទិននឹងភាគកម្មនៅក្នុងទ្រព្យសកម្មគ្រប់គ្រងរួម ភាគីរួមទុនត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុៈ**

**(ក) ចំណែករបស់ភាគីរួមទុននៃទ្រព្យសកម្មគ្រប់គ្រងរួម ដែលបានចាត់ថ្នាក់ដោយយោងទៅតាម លក្ខណៈ នៃទ្រព្យសកម្ម**

**(ខ) បំណុលណាដែលបានកើតឡើង**

**(គ) ចំណែករបស់ភាគីរួមទុននៃបំណុលណាមួយ ដែលកើតឡើង រួមជាមួយនឹងភាគីរួមទុនផ្សេងទៀត នៅក្នុងក្រុមហ៊ុនរួមទុន**

**(ឃ) ចំណូលណាមួយពីការលក់ និងការប្រើប្រាស់នៃចំណែករបស់ ភាគីរួមទុននៃទិន្នផលនៃក្រុមហ៊ុនរួមទុន រួមជាមួយនឹងចំណែក របស់ភាគីរួមទុននៃចំណាយណាមួយដែលបានកើតឡើងដោយ ក្រុមហ៊ុនរួមទុន និង**

**(ង) ចំណាយណាមួយដែលបានកើតឡើងទាក់ទិននឹងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន ។**

២២ ទាក់ទិននឹងភាគកម្មរបស់ភាគីរួមទុននៃទ្រព្យសកម្មគ្រប់គ្រងរួម ភាគីរួមទុននីមួយបញ្ចូលឯកសារគណនេយ្យរបស់ខ្លួន ហើយទទួលស្គាល់នៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនៈ

(ក) ចំណែករបស់ភាគីរួមទុននៃទ្រព្យសកម្មរួមដែលបានចាត់ថ្នាក់ ដោយយោងទៅតាមប្រភេទនៃទ្រព្យសកម្មជាជាងការវិនិយោគ។ឧទាហរណ៍ ចំណែក នៃបំពង់បង្ហូរប្រេងគ្រប់គ្រងរួម ត្រូវបានចាត់ថ្នាក់ជាទ្រព្យរោងចក្រ និងបរិក្ខារ។

(ខ) បំណុលណាមួយដែលបានកើតឡើង ជាឧទាហរណ៍ បំណុលដែល

បានកើតឡើង នៅក្នុងការធ្វើហិរញ្ញប្បទានចំណែកទ្រព្យសកម្ម របស់ខ្លួន ។

(គ) ចំណែករបស់ភាគីរួមទុន នៃបំណុលណាមួយដែលបានកើតឡើងរួមជាមួយភាគីរួមទុនផ្សេងទៀតនៅក្នុងក្រុមហ៊ុនរួមទុន

(ឃ) ចំណូលណាមួយពីការលក់ ឬការប្រើប្រាស់ នៃចំណែកទិន្នផលនៃក្រុមហ៊ុនរួមទុន រួមជាមួយចំណែករបស់ភាគីរួមទុន នៃចំណាយណាមួយដែលបានកើតឡើងដោយក្រុមហ៊ុនរួមទុន ។

(ង) ចំណាយណាមួយដែលបានកើតឡើងទាក់ទិននឹងភាគកម្មរបស់ ភាគីរួមទុននៅក្នុងក្រុមហ៊ុនរួមទុន ជាឧទាហរណ៍ ចំណាយដែលទាក់ទិននឹងការធ្វើហិរញ្ញប្បទានភាគកម្ម នៅក្នុងទ្រព្យសកម្មរបស់ភាគីរួមទុន និងការលក់ចំណែកទិន្នផលរបស់ភាគីរួមទុន ។

ពីព្រោះតែទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃភាគីរួមទុន ពុំមានការកែសម្រួល ឬនីតិបង្រួមផ្សេងទៀតណាមួយ ត្រូវបានតម្រូវឱ្យមានទាក់ទិននឹងធាតុទាំងនេះទេ នៅពេលដែលភាគីរួមទុនដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ។

២៣ ការទទួលស្គាល់នៃទ្រព្យសកម្មគ្រប់គ្រងរួម ឆ្លុះបញ្ចាំងពីភាពសំខាន់ និងភាពពិតសេដ្ឋកិច្ច ហើយជាទូទៅ ទម្រង់ច្បាប់នៃក្រុមហ៊ុនរួមទុន ។ ឯកសារគណនេយ្យដាច់ដោយឡែករបស់ក្រុមហ៊ុនរួមទុនផ្ទាល់ អាចត្រូវបានកម្រិតត្រឹមចំណាយទាំងនោះដែលបានកើតឡើងជារួមដោយភាគីរួមទុន និងចុងក្រោយបង្អស់ត្រូវបានរ៉ាប់រង ដោយក្រុមហ៊ុនរួមទុនដោយយោងទៅតាមចំណែកដែលបានព្រមព្រៀងគ្នា។ របាយការណ៍ហិរញ្ញវត្ថុអាចមិនត្រូវបាន

រៀបចំសម្រាប់ក្រុមហ៊ុនរួមទុន ទោះបីជាក្រុមហ៊ុនរួមទុនអាចរៀបចំគណនី គ្រប់គ្រងដូច្នេះភាគីរួមទុនអាចវាយតម្លៃពីលទ្ធផលរបស់ក្រុមហ៊ុនរួមទុន ។

## អង្គភាពគ្រប់គ្រងរួម

២៤ អង្គភាពគ្រប់គ្រងរួម គឺជាក្រុមហ៊ុនរួមទុន ដែលពាក់ព័ន្ធនឹងការបង្កើត សារជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងទៀតដែលភាគីរួមទុន មានភាគកម្ម។ អង្គភាពធ្វើកិច្ចប្រតិបត្តិការតាមរបៀបដូចគ្នានឹងអង្គភាព ផ្សេងទៀត លើកលែងតែការរៀបចំកិច្ចព្រមព្រៀងរវាងភាគីរួមទុនបង្កើត ការគ្រប់គ្រងរួមលើសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាព ។

២៥ អង្គភាព គ្រប់គ្រងរួមទុនគ្រប់គ្រងទ្រព្យសកម្មនៃក្រុមហ៊ុនរួមទុនកើតឡើងនូវបំណុល និងចំណាយ និងរកបានចំណូល។ អង្គភាពអាចចុះកិច្ចសន្យាក្រោមឈ្មោះរបស់គេ និងគៀងគរហិរញ្ញវត្ថុ សម្រាប់គោលបំណងនៃសកម្មភាពរបស់ក្រុមហ៊ុនរួមទុន ។ អង្គភាពរួមទុននីមួយៗមានសិទ្ធិ ដើម្បីទទួលបានចំណែកផលចំណេញរបស់អង្គភាពគ្រប់គ្រងរួម ទោះបីជាអង្គភាពគ្រប់គ្រងរួមខ្លះក៏ជាប់ពាក់ព័ន្ធនៃការចែកទិន្នផលនៃក្រុមហ៊ុនរួមទុន ។

២៦ ឧទាហរណ៍រួមរបស់អង្គភាពគ្រប់គ្រង គឺនៅពេលដែលអង្គភាពពីរបញ្ចូលសកម្មភាពរបស់គេនៅក្នុងខ្សែសង្វាក់ពាណិជ្ជកម្មជាក់លាក់ ដោយការផ្ទេរទ្រព្យសកម្ម និងបំណុលទាក់ទិនទៅក្នុងអង្គភាពគ្រប់គ្រងរួម ។ ឧទាហរណ៍មួយផ្សេងទៀត គឺនៅពេលដែលអង្គភាពមួយចាប់ផ្តើមអាជីវកម្មនៅក្នុងប្រទេសក្រៅភ្ជាប់នឹង រដ្ឋាភិបាល ឬភ្នាក់ងារផ្សេងទៀតនៅក្នុងប្រទេសនោះ ដោយការបង្កើតអង្គភាពដាច់ដោយឡែក ដែលត្រូវបានគ្រប់គ្រងរួមដោយ

អង្គភាព និងរដ្ឋាភិបាល ឬ ភ្នាក់ងារ ។

២៧ អង្គភាពគ្រប់គ្រងរួមជាច្រើនស្រដៀងគ្នា ក្នុងភាពសំខាន់ចំពោះក្រុមហ៊ុនរួមទុនទាំងនោះដែលគេហៅថា កិច្ចប្រតិបត្តិការគ្រប់គ្រងរួម ឬទ្រព្យសកម្មគ្រប់គ្រងរួម ។ ឧទាហរណ៍ ភាគីរួមទុនអាចផ្ទេរទ្រព្យសកម្មគ្រប់គ្រងរួមដូចជា បំពង់បង្ហូរប្រេង ទៅក្នុងអង្គភាពគ្រប់គ្រងរួមសម្រាប់ហេតុផលពន្ធដារ ឬហេតុផលផ្សេងទៀត ។ ស្រដៀងគ្នានេះ ភាគីរួមទុនអាចដាក់ទុនចូលទៅ ក្នុងទ្រព្យសកម្មអង្គភាពរួមទុន ដែលនឹងត្រូវបានធ្វើកិច្ចប្រតិបត្តិការរួម។ កិច្ចប្រតិបត្តិការគ្រប់គ្រងរួម ក៏ទាក់ទិននឹងការបង្កើតឡើងនូវអង្គភាពគ្រប់គ្រងរួម ដើម្បីដោះស្រាយនូវទិដ្ឋភាពសកម្មភាពជាក់លាក់ជាឧទាហរណ៍ ការរចនា ការធ្វើទីផ្សារ ការចែកចាយ ឬសេវាបន្ទាប់ ការលក់នៃ ផលិតផល ។

២៨ អង្គភាពគ្រប់គ្រងរួមរក្សានូវឯកសារគណនេយ្យផ្ទាល់ខ្លួន និងរៀបចំ ព្រមទាំងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមរបៀបដូចគ្នានឹងអង្គភាពផ្សេងទៀត ដោយស្របនឹងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

២៩ ភាគីរួមទុននីមួយៗទៅដាក់សាច់ប្រាក់ឬធនធានផ្សេងទៀតទៅអង្គភាពគ្រប់គ្រងរួម ។ ការដាក់ទុនវិនិយោគទាំង នេះត្រូវបានបញ្ចូលនៅក្នុងឯកសារគណនេយ្យរបស់ភាគីរួមទុន និងត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុជាការវិនិយោគនៅក្នុងអង្គភាពគ្រប់គ្រងរួម ។

**របាយការណ៍ហិរញ្ញវត្ថុរបស់ភាគីរួមទុន**

**ការបង្រួមតាមសមាមាត្រ**

៣០ **ភាគីរួមទុនត្រូវទទួលស្គាល់ភាគកម្មរបស់ខ្លួន នៅក្នុងអង្គភាពគ្រប់គ្រងរួម ដោយប្រើការបង្រួមតាមសមាមាត្រ ឬវិធីសាស្ត្រជាជម្រើស ដែលបានរៀបចំនៅក្នុងកថាខណ្ឌ៣៨ ។ នៅពេលដែលការបង្រួមតាមសមាមាត្រ ត្រូវបានប្រើទម្រង់រាយការណ៍ចំនួនពីរដែលបានកំណត់អត្តសញ្ញាណ ខាងក្រោមត្រូវបានប្រើ ។**

៣១ ភាគីរួមទុនទទួលស្គាល់ភាគកម្មរបស់ខ្លួននៅក្នុងអង្គភាពគ្រប់គ្រងរួមដោយប្រើទម្រង់រាយការណ៍ចំនួនពីរ សម្រាប់ការបង្រួមតាមសមាមាត្រ ដោយមិន គិតថាតើ អង្គភាពមានការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬថាតើ អង្គភាពរៀបរាប់ពីរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជារបាយការណ៍ហិរញ្ញ វត្ថុរួម ។

៣២ នៅពេលទទួលស្គាល់ភាគកម្មនៅក្នុងក្រុមហ៊ុនគ្រប់គ្រងរួម វាមានសារៈសំខាន់ដែលភាគីរួមទុនបង្ហាញពី ភាពសំខាន់និងភាពពិតប្រាកដនៃការរៀបចំជាជាងរចនាសម្ព័ន្ធជាក់លាក់របស់ក្រុមហ៊ុនរួមទុនឬទម្រង់ ។ នៅក្នុងអង្គភាពគ្រប់គ្រងរួម ភាគីរួមទុនមានការគ្រប់គ្រងរួមលើចំណែករបស់ខ្លួន នៃអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតតាមរយៈចំណែករបស់ខ្លួននៃទ្រព្យសកម្ម និងបំណុលនៃក្រុមហ៊ុនរួមទុន ។ ភាពសំខាន់ និងភាពពិតប្រាកដផ្នែកសេដ្ឋកិច្ចត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ភាគីរួមទុន នៅពេលដែលភាគីរួមទុនទទួលស្គាល់ភាគកម្ម នៅក្នុង

ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនៃអង្គភាពគ្រប់គ្រងរួម ដោយការប្រើប្រាស់ទម្រង់រាយការណ៍មួយ នៃទម្រង់ទាំងពីរសម្រាប់ការបង្រួមតាមសមាមាត្រដែលបានបរិយាយនៅក្នុងកថាខណ្ឌ ៣៤ ។

៣៣ ការអនុវត្តនៃការបង្រួមតាមសមាមាត្រ មានន័យថារបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៃភាគីរួមទុនរួមបញ្ចូល នូវចំណែកនៃទ្រព្យសកម្ម ដែលអង្គភាពគ្រប់គ្រងរួម និងចំណែករបស់ខ្លួននៃបំណុលដែលអង្គភាពទទួលខុសត្រូវរួម។ របាយការណ៍លទ្ធផលលម្អិតផ្សេងទៀតនៃភាគីរួមទុនរួមបញ្ចូលនូវចំណែកនៃចំណូល និងចំណាយនៃអង្គភាពគ្រប់គ្រងរួម។ នីតិវិធីជាច្រើនដែលសមស្របសម្រាប់ការអនុវត្តនៃការបង្រួម តាមសមាមាត្រគឺស្រដៀងគ្នានឹងនីតិវិធីដែលការបង្រួមនៃការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានចែង នៅក្នុង ស.គ.អ.ក ២៧។

៣៤ ទម្រង់រាយការណ៍ខុសៗគ្នាអាចត្រូវបានប្រើដើម្បីផ្តល់ឥទ្ធិពល ចំពោះការបង្រួមតាមសមាមាត្រ។ ភាគីរួមទុន អាចបញ្ចូលចំណែកនៃទ្រព្យសកម្ម បំណុល ចំណូល និង ចំណាយនីមួយៗ នៃអង្គភាពគ្រប់គ្រងរួមជាមួយនឹងធាតុស្រដៀងគ្នា តាមបន្ទាត់គណនីពីមួយទៅមួយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ជាឧទាហរណ៍ ភាគី រួមទុនអាចបញ្ចូលគ្នានូវចំណែករបស់ខ្លួននៃសន្និធិរបស់អង្គភាពគ្រប់គ្រងរួមជាមួយនឹងសន្និធិរបស់ខ្លួន និងចំណែករបស់នៃទ្រព្យ រោងចក្រ និង បរិក្ខាររបស់អង្គភាពគ្រប់គ្រងជាមួយនឹងទ្រព្យរោចក្រ និងបរិក្ខាររបស់ខ្លួន។ ជាជម្រើស ភាគីរួមទុនអាចបញ្ចូលធាតុបន្ទាត់ គណនីដាច់ដោយឡែកសម្រាប់ចំណែករបស់ខ្លួននៃទ្រព្យ សកម្ម បំណុល ចំណូល និងចំណាយ នៃអង្គភាពគ្រប់គ្រងរួមនៅក្នុងរបាយការណ៍

ហិរញ្ញវត្ថុ ។ ជាឧទាហរណ៍ ភាគីរួមទុនអាចបង្ហាញចំណែករបស់ខ្លួននៃទ្រព្យសកម្មរយៈពេលខ្លី នៃអង្គភាពគ្រប់គ្រងដាច់ដោយឡែកជា ផ្នែកមួយនៃទ្រព្យ សកម្មរយៈពេលខ្លីរបស់ខ្លួន ភាគីរួមទុនអាចបង្ហាញចំណែករបស់ខ្លួននៃទ្រព្យ រោងចក្រ និងបរិក្ខារនៃអង្គភាពគ្រប់គ្រងរួមដាច់ដោយឡែកជាផ្នែក នៃទ្រព្យ រោងចក្រ និងបរិក្ខាររបស់ខ្លួន ។ ទម្រង់រាយការណ៍ទាំងពីរនេះ បង្ហាញនៅក្នុងការរាយការណ៍ទឹកប្រាក់សំខាន់ៗ នៃរបាយការណចំណេញ ឬខាត និងការចាត់ថ្នាក់សំខាន់ៗនៃទ្រព្យ បំណុល ចំណូល និងចំណាយនីមួយៗ ទម្រង់ទាំងពីរអាចទទួលយកបាន សម្រាប់គោលបំណងនៃស្តង់ដានេះ។

៣៥ ទម្រង់មួយណាក៏ដោយ ក៏ត្រូវបានប្រើ ដើម្បីផ្តល់នូវឥទ្ធិពលចំពោះការបង្រួមតាមសមាមាត្រ វាមិនសមស្របទេដើម្បីធ្វើការកាត់កងទ្រព្យសកម្ម ឬបំណុលដោយការកាត់បន្ថយបំណុលផ្សេងទៀត ឬទ្រព្យសកម្មផ្សេងទៀត ឬចំណូល ឬចំណាយណាមួយដោយការកាត់បន្ថយនៃចំណាយ ឬចំណូលផ្សេងទៀត លុះត្រាតែសិទ្ធិស្របច្បាប់នៃការកាត់កង ត្រូវបានផ្តល់ឲ្យ ហើយការកាត់កងតំណាងឲ្យការរំពឹងចំពោះការទទួលស្គាល់ទ្រព្យសកម្ម ឬការទូទាត់បំណុល ។

**៣៦ ភាគីរួមទុនត្រូវឈប់ប្រើប្រាស់ការបង្រួមតាមសមាមាត្រពីកាលបរិច្ឆេទដែលភាគីរួមទុនឈប់មានការ គ្រប់គ្រងរួមលើអង្គភាពគ្រប់គ្រងរួម ។**

៣៧ ភាគីរួមទុន មិនបន្តការប្រើប្រាស់ការបង្រួម តាមសមាមាត្រចាប់ពីកាលបរិច្ឆេទដែលភាគីរួមទុនឈប់ចែករំលែកការគ្រប់គ្រងនៃអង្គភាពគ្រប់គ្រងរួម ។ ជាឧទាហរណ៍ នេះអាចកើតឡើង នៅពេលដែលភាគីរួមទុន លក់

ចោលនូវភាគកម្មរបស់ខ្លួន ឬនៅពេលដែលការហាមឃាត់ពីផ្នែកខាងក្រៅត្រូវបានកំណត់លើអង្គភាព គ្រប់គ្រងរួមដែលភាគីរួមទុនឈប់មានការគ្រប់គ្រងរួម ។

**វិធីសាស្ត្រមូលធន**

៣៨ **ជាជម្រើសមួយទៀតចំពោះការបង្រួមតាមសមាមាត្រដែលបានរៀបរាប់នៅក្នុង កថាខណ្ឌ ៣០ ភាគីរួមទុន ត្រូវទទួលស្គាល់ភាគកម្មរបស់ខ្លួននៅក្នុងអង្គភាពគ្រប់គ្រងរួមដោយប្រើវិធីសាស្ត្រមូលធន។**

៣៩ ភាគីរួមទុនទទួលស្គាល់ភាគកម្មរបស់ខ្លួននៅក្នុងអង្គភាពគ្រប់គ្រងរួមដោយប្រើវិធីសាស្ត្រមូលធនដោយមិន គិតថាតើភាគីរួមទុនមានការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬថាតើភាគីរួមទុនចាត់ទុករបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជារបាយការណ៍ហិរញ្ញវត្ថុរួម ។

៤០ ភាគីរួមទុនខ្លះទទួលស្គាល់ភាគកម្មរបស់គេ នៅក្នុងអង្គភាពគ្រប់គ្រងរួមដោយប្រើវិធីសាស្ត្រមូលធន ដូចបាន រៀបរាប់នៅក្នុង ស.គ.អ.ក ២៨ ។ ការប្រើប្រាស់វិធីសាស្ត្រមូលធនត្រូវបានគាំទ្រដោយអ្នកដែលបានប្រឆាំងថាវាមិនសមស្របដើម្បីបញ្ចូលធាតុបានគ្រប់គ្រងជាមួយនឹងធាតុគ្រប់គ្រងរួម និងដោយអ្នកដែលជឿថា ភាគីរួមទុនមានឥទ្ធិពលសំខាន់ ជាជាងការគ្រប់គ្រងរួម នៅក្នុងអង្គភាពគ្រប់គ្រងរួម។ ស្តង់ដានេះមិនណែនាំឲ្យប្រើវិធីសាស្ត្រមូលធនពីព្រោះតែការបង្រួមតាមសមាមាត្រគួរតែបង្ហាញពីភាពសំខាន់ និងភាពពិតផ្នែក សេដ្ឋកិច្ចនៃភាគកម្មរបស់ភាគីរួមទុន នៅក្នុងអង្គភាពគ្រប់គ្រងរួមដែលត្រូវនិយាយថាការគ្រប់គ្រងលើចំណែករបស់ ភាគីរួម

ទុននៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ។ ទោះបីជាយ៉ាងណាក៏ដោយ ស្តង់ដានេះអនុញ្ញាតឱ្យមានការប្រើប្រាស់វិធីសាស្ត្រមូលធន ជាការទទួលស្គាល់មួយទៀត នៅពេលដែលទទួលស្គាល់ភាគកម្មនៅក្នុង អង្គភាពគ្រប់គ្រងរួម ។

**៤១ ភាគីរួមទុនត្រូវបញ្ឈប់ការប្រើប្រាស់វិធីសាស្ត្រមូលធនចាប់ពីកាលបរិច្ឆេទដែលភាគីរួមទុនឈប់មាន ការគ្រប់គ្រងរួមលើ ឬមានឥទ្ធិពលសំខាន់នៅក្នុង អង្គភាពគ្រប់គ្រងរួម ។**

**ការលើកលែងចំពោះការបង្រួមតាមសមាមាត្រ និង វិធីសាស្ត្រមូលធន**

**៤២ ភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួម ដែលត្រូវបានចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ដោយអនុលោមតា ស.រ.ហ.អ.ក ៥ ត្រូវបានធ្វើគណនេយ្យកម្មដោយអនុលោមតាម ស.រ.ហ.អ.ក នោះ ។**

៤៣ នៅពេលដែលភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួម ដែលការពីមុនត្រូវបានចាត់ថ្នាក់ជាការរក្សាសម្រាប់លក់មិនបំពេញលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានចាត់ថ្នាក់បែបនេះ ភាគកម្មត្រូវបានធ្វើគណនេយ្យកម្មដោយប្រើ ការបង្រួមតាមសមាមាត្រ ឬវិធីសាស្ត្រមូលធនចាប់ពីកាលបរិច្ឆេទនៃការចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ ។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទចាប់ តាំងពីការចាត់ថ្នាក់ជាការរក្សាទុកសម្រាប់លក់ត្រូវបានធ្វើវិសោធនកម្ម ។

៤៤ [លុបចោល]

**៤៥ នៅពេលដែលអ្នកវិនិយោគឈប់មានការគ្រប់គ្រងរួមលើអង្គភាពមួយ អ្នក**

វិនិយោគត្រូវធ្វើគណនេយ្យកម្ម ការវិនិយោគដែលនៅសល់ដោយអនុលោមតាម ស.រ.ហ.អ.ក ៩ ចាប់ពីកាលបរិច្ឆេទនោះ ដោយដឹងថា អង្គភាពគ្រប់គ្រងរួមមុនមិនក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសមាគត ។ ចាប់ពីកាលបរិច្ឆេទដែលអង្គភាព រួមទុនក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ អ្នកវិនិយោគ អ្នកវិនិយោគត្រូវធ្វើគណនេយ្យកម្មភាគកម្ម របស់ខ្លួន ដោយអនុលោមតាម ស.គ.អ.ក ២៧ និង ស.រ.ហ.អ ៣ *ការបញ្ចូល អាជីវកម្មរួមគ្នា* (ដូចបានកែប្រែ នៅក្នុងឆ្នាំ ២០០៨)។ ចាប់ពីកាលបរិច្ឆេទ ដែលអង្គភាពគ្រប់គ្រងរួមក្លាយជាសមាគតរបស់អ្នកវិនិយោគ អ្នកវិនិយោគ ត្រូវធ្វើគណនេយ្យកម្មភាគកម្មរបស់ខ្លួនដោយអនុលោមតាម ស.គ.អ.ក ២៨។ នៅពេល បាត់បង់ការគ្រប់គ្រង អ្នកវិនិយោគត្រូវវាស់វែងតាមតម្លៃ សមស្របនូវការវិនិយោគដែលអ្នកវិនិយោគ រក្សានៅក្នុងអង្គភាពគ្រប់គ្រង រួមមុន។ អ្នកវិនិយោគត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នូវភាពខុសគ្នារវាងៈ

(ក) តម្លៃសមស្របនៃការវិនិយោគដែលបានរក្សាទុក និងចំណូលពីការលក់ចោលនៃភាគកម្មជាផ្នែកនៅក្នុងអង្គភាពគ្រប់គ្រងរួម និង

(ខ) តម្លៃយោងនៃការវិនិយោគនៅកាលបរិច្ឆេទ ដែលការគ្រប់គ្រងរួមត្រូវបានបាត់បង់។

៤៥ក នៅពេលដែលការវិនិយោគឈប់ជា អង្គភាពគ្រប់គ្រងរួមតទៅទៀត ហើយត្រូវបានធ្វើគណនេយ្យកម្មដោយអនុលោមតាម ស.រ.ហ.អ. ៩ តម្លៃសមស្របនៃការវិនិយោគ នៅពេលដែលអង្គភាពឈប់ជាអង្គភាព គ្រប់គ្រងរួមត្រូវបានចាត់ទុកជាតម្លៃសមស្របរបស់ខ្លួន នៅពេលទទួលស្គាល់លើកដំបូងជាទ្រព្យសកម្ម ហិរញ្ញវត្ថុដោយអនុលោមតាម ស.រ.ហ.អ.ក ៩ ។

៤៥ខ ប្រសិនបើអ្នកវិនិយោគបាត់បង់ការគ្រប់គ្រងរួមនៃអង្គភាព អ្នកវិនិយោគត្រូវធ្វើគណនេយ្យកម្មទឹកប្រាក់ទាំងអស់ ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀតដែលទាក់ទិននឹងអង្គភាពនោះតាមមូលដ្ឋានដូចគ្នានឹងមូលដ្ឋាន ដែលត្រូវបានតម្រូវឱ្យមានប្រសិនបើអង្គភាពគ្រប់គ្រងរួមបានលក់ចោលដោយផ្ទាល់នូវទ្រព្យសកម្ម ឬបំណុលទាក់ទិន។ ដូច្នេះ ប្រសិនបើចំណេញ ឬខាត ដែលបានទទួលស្គាល់ពីមុននៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀតអាចត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញឬខាតនៅពេលការលក់ចោលទ្រព្យសកម្ម ឬបំណុលទាក់ទិននោះ នោះអ្នកវិនិយោគចាត់ថ្នាក់ឡើងវិញនូវចំណេញ ឬខាតពីគណនីដើមទុនទៅរបាយការណ៍ចំណេញឬខាត (ជាការកែសម្រួលការចាត់ថ្នាក់) នៅពេលដែលអ្នក វិនិយោគបាត់បង់ការគ្រប់គ្រងរួមនៃអង្គភាព។ ឧទាហរណ៍ ប្រសិនបើអង្គភាពគ្រប់គ្រងរួមមានភាពខុសគ្នាពី ការប្តូរប្រាក់ប្តូកបន្ត ដែលទាក់ទិននឹងកិច្ចប្រតិបត្តិការក្រៅប្រទេស និងអ្នកវិនិយោគបាត់បង់ការគ្រប់គ្រងរួមនៃអង្គភាពនោះអ្នកវិនិយោគត្រូវចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញឬខាត នូវចំណេញឬខាតដែលបានទទួលស្គាល់ពីមុន នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀតទាក់ទិននឹងកិច្ចប្រតិបត្តិការក្រៅប្រទេស ។ ប្រសិនបើភាគកម្មកាន់កាប់របស់អ្នកវិនិយោគនៅក្នុង អង្គភាពគ្រប់គ្រងរួមត្រូវបានកាត់បន្ថយ ប៉ុន្តែការ វិនិយោគបន្តជាអង្គភាព គ្រប់គ្រងរួម នោះអ្នកវិនិយោគត្រូវចាត់ថ្នាក់ឡើងវិញនូវរបាយការណ៍ចំ ណេញ ឬខាត តែទឹកប្រាក់តាមសមាមាត្រនៃចំណេញ ឬខាតដែលបាន ទទួលស្គាល់ពីមុននៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀ

ត។

**របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកនៃភាគីរួមទុន**

៤៦ **ភាគកម្មនៅក្នុងអង្គភាពគ្រប់គ្រងរួមត្រូវបានធ្វើគណនេយ្យកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកដោយអនុលោមតាមកថាខណ្ឌ ៣៨-៤៣ នៃ ស.គ.អ.ក ២៧ ។**

៤៧ ស្តង់ដានេះមិនប្រគល់សិទ្ធិទៅឲ្យអង្គភាពណា ដែលផលិតរបាយការណ៍-ហិរញ្ញវត្ថុដាច់ដោយឡែក ដែលអាចរកបានសម្រាប់ការប្រើប្រាស់ជាសាធារណៈ ។

ប្រតិបត្តិការរវាងភាគីរួមទុននិងក្រុមហ៊ុនរួមទុន

៤៨ នៅពេលដែលភាគីរួមទុន ដាក់ទុនឬលក់ទ្រព្យសកម្មទៅឱ្យក្រុមហ៊ុនរួមទុន ការទទួលស្គាល់នៃផ្នែកណាមួយ នៃចំណេញឬខាតពីការប្រតិបត្តិការត្រូវ ឆ្លុះបញ្ចាំងពីភាពសំខាន់នៃប្រតិបត្តិការ ។ ខណៈពេលដែលទ្រព្យសកម្ម ត្រូវបានរក្សាទុកដោយក្រុមហ៊ុនរួមទុន និងដោយដឹងថាភាគីរួមទុន បានផ្ទេរហានីភ័យ និងផលប្រយោជន៍សំខាន់ៗនៃកម្មសិទ្ធិភាគីរួមទុន ត្រូវទទួលស្គាល់តែចំណែកនៃចំណេញឬខាតដែលបានបែងចែកចំពោះ ភាគកម្មនៃភាគីរួមទុនផ្សេងទៀត* ។ ភាគីរួមទុនត្រូវទទួលស្គាល់ទឹកប្រាក់ទាំងអស់ នៃការខាតណាមួយនៅពេលដែលដាក់ទុន ឬការលក់ផ្តល់ភស្តុតាងពីការថយចុះតម្លៃទទួលស្គាល់ពិត នៃទ្រព្យសកម្មរយៈពេលខ្លី ឬ ការខាតពីការធ្លាក់ចុះតម្លៃ ។

៤៩ នៅពេលដែលភាគីរួមទុនទិញទ្រព្យសកម្មពីក្រុមហ៊ុនរួមទុនភាគីរួមទុន មិន

ត្រូវទទួលស្គាល់ចំណែករបស់ខ្លួន នៃផលចំណេញនៃក្រុមហ៊ុនរួមទុន ពីប្រតិបត្តិការរហូតដល់ភាគីរួមទុនលក់ទ្រព្យសកម្មបន្តទៅឱ្យភាគី ឯករាជ្យមួយ ។ ភាគីរួមទុនត្រូវទទួលស្គាល់ចំណែករបស់ខ្លួននៃការខាតបង់ ដែលកើតចេញពីប្រតិបត្តិការ ទាំងនេះតាមរបៀបដូចគ្នានឹងផលចំណេញ ដែរ លើកលែងតែការខាតបង់នោះត្រូវបានទទួលស្គាល់ ភ្លាមៗ នៅពេល ដែលការខាតទាំងនោះតំណាងឱ្យការកាត់បន្ថយតម្លៃទទួលស្គាល់ពិតនៃទ្រព្យសកម្មរយៈពេលខ្លី ឬ ការខាតពីការធ្លាក់ចុះតម្លៃ ។

៥០ ដើម្បីវាយតម្លៃថាតើប្រតិបត្តិការរវាងភាគីរួមទុន និងក្រុមហ៊ុនរួមទុនផ្តល់នូវភស្តុតាងពីការធ្លាក់ចុះតម្លៃ ទ្រព្យសកម្ម ភាគីរួមទុនកំណត់ពីទឹកប្រាក់ត្រូវទទួលបានមកវិញនៃទ្រព្យសកម្មដោយអនុលោមតាម ស.គ.អ.ក ៣៦ *ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម* ។ នៅក្នុងការកំណត់តម្លៃ កំពុងប្រើប្រាស់ភាគីរួមទុនប៉ាន់ស្មាន ពីលំហូរសាច់ប្រាក់នាពេលអនាគតពីទ្រព្យសកម្មតាមមូលដ្ឋាននៃការប្រើប្រាស់បន្តនៃទ្រព្យសកម្ម និងការលក់ចោលចុងក្រោយបង្អស់ដោយក្រុមហ៊ុនរួមទុន ។

## ការរាយការណ៍ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃអ្នកវិនិយោគ

**៥១ អ្នកវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុនដែលមិនមានការគ្រប់គ្រងរួមត្រូវធ្វើគណនេយ្យកម្មចំពោះការវិនិយោគ នោះដោយអនុលោមតាម ស.រ.ហ.អ.ក ៩ ប្រសិនបើអ្នកវិនិយោគមានឥទ្ធិពលសំខាន់នៅក្នុងក្រុមហ៊ុនរួមទុន ត្រូវអនុលោមតាម ស.គ.អ.ក ២៨។**

## ប្រតិបត្តិករនៃក្រុមហ៊ុនរួមទុន

**៥២ ប្រតិបត្តិករ ឬ អ្នកគ្រប់គ្រងនៃក្រុមហ៊ុនរួមទុនត្រូវធ្វើគណនេយ្យកម្មចំពោះថ្លៃឈ្នួលដោយអនុលោមតាម ស.គ.អ.ក ១៨ *ផលរបរ* ។**

៥៣ ភាគីរួមទុនមួយឬច្រើនអាចធ្វើជាប្រតិបត្តិករ ឬជាអ្នកគ្រប់គ្រងនៃក្រុមហ៊ុនរួម ។ ប្រតិបត្តិករជាធម្មតាបានបង់ថ្លៃឈ្នួលគ្រប់គ្រង សម្រាប់ការងារបែបនេះ ។ ថ្លៃឈ្នួលនេះត្រូវបានធ្វើគណនេយ្យកម្ម ដោយក្រុមហ៊ុនរួមទុនជាចំណាយ ។

## ការលាតត្រដាងព័ត៌មាន

**៥៤ ភាគីរួមទុនត្រូវលាតត្រដាងទឹកប្រាក់សរុបនៃបំណុលយថាហេតុ លុះត្រាតែភវនីយនៃការខាតស្ថិតនៅឆ្ងាយដាច់ដោយឡែកពីទឹកប្រាក់ នៃបំណុលយថា-ហេតុ ផ្សេងទៀតៈ**

(ក) បំណុលយថាហេតុដែលភាគីរួមទុនបានកើតមានឡើងទាក់ទិន នឹងភាគកម្មរបស់ខ្លួននៅក្នុង ក្រុមហ៊ុនរួមទុន និងចំណែករបស់ ខ្លួននៅក្នុងបំណុលយថាហេតុនីមួយៗ ដែលត្រូវបានធ្វើឱ្យកើតមានឡើងរួមគ្នាជាមួយភាគីរួមទុនផ្សេងទៀត

(ខ) ចំណែករបស់ខ្លួននៃបំណុលយថាហេតុនៃក្រុមហ៊ុនរួម ដែលអាចទទួលខុសត្រូវជាយថាតហេតុ និង

(គ) បំណុលយថាហេតុទាំងនោះដែលកើតឡើងពីព្រោះភាគីរួមទុន

ទទួលខុសត្រូវជាយថាហេតុ សម្រាប់បំណុលរបស់ភាគីរួមទុនផ្សេង ទៀត នៃក្រុមហ៊ុនរួមទុន ។

៥៥ ភាគីរួមទុនត្រូវលាតត្រដាងពីទឹកប្រាក់សរុបនៃការសន្យាដូចខាងក្រោម ទាក់ទិននឹងភាគកម្មរបស់ខ្លួន នៅក្នុងក្រុមហ៊ុនរួមទុនដាច់ដោយឡែក ពីការសន្យាផ្សេងទៀតៈ

(ក) ការសន្យាដើមទុនណាមួយរបស់ភាគីរួមទុនទាក់ទិននឹងភាគកម្ម របស់ខ្លួននៅក្នុងក្រុមហ៊ុនរួមទុន និងចំណែករបស់ខ្លួននៅក្នុងការសន្យាដើមទុនដែលត្រូវបានកើតមានឡើងរួមគ្នាជាមួយភាគីរួមទុនផ្សេងទៀត និង

(ខ) ចំណែករបស់ខ្លួននៃការសន្យាដើមទុននៃក្រុមហ៊ុនរួមទុនផ្ទាល់ ។

៥៦ ភាគីរួមទុនត្រូវលាតត្រដាងពីបញ្ជី និងការបរិយាយពីការប្រាក់នៅក្នុង ក្រុមហ៊ុនរួមទុនសំខាន់ៗ និងសមាមាត្រនៃភាគកម្មកាន់កាប់ដែលរក្សាទុក នៅក្នុងអង្គភាពគ្រប់គ្រងរួម ។ ភាគីរួមទុនមួយដែលទទួលស្គាល់ភាគកម្ម របស់ខ្លួននៅក្នុងអង្គភាពគ្រប់គ្រងរួម ដោយប្រើទម្រង់រាយការណ៍តាមបន្ទាត់គណនីសម្រាប់ការបង្រួមតាមសមាមាត្រ ឬវិធីសាស្ត្រមូលធន ត្រូវលាតត្រដាងពីទឹកប្រាក់សរុបនៃទ្រព្យសកម្មរយៈពេលខ្លីនីមួយៗ ទ្រព្យសកម្មរយៈពេលវែង បំណុលរយៈពេលខ្លី បំណុលរយៈពេលវែង ចំណូល និងចំណាយដែលទាក់ទិននឹងភាគកម្មរបស់ខ្លួននៅក្នុងក្រុមហ៊ុនរួមទុន ។

៥៧ ភាគីរួមទុនត្រូវលាតត្រដាងពីវិធីសាស្ត្រដែលភាគីរួមទុនប្រើដើម្បីទទួលស្គាល់ភាគកម្មរបស់ខ្លួននៅក្នុង អង្គភាពគ្រប់គ្រងរួម ។

៥៨ អង្គភាពមួយ ត្រូវប្រើស្តង់ដានេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាពមួយអនុវត្តស្តង់ដានេះសម្រាប់ការិយបរិច្ឆេទមួយដែលចាប់ផ្តើមមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ ។

៥៨ក ស.គ.អ.ក២៧ (ដូចបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៨) បានធ្វើវិសោធន-កម្ម កថាខណ្ឌ៤៥ និង ៤៦ និង បានបន្ថែមកថាខណ្ឌ៤៥ក និង ៤៥ខ ។ អង្គភាពមួយត្រូវប្រើវិសោធនកម្ម ចំពោះកថាខណ្ឌ៤៦ជាប្រតិសកម្ម និងវិសោធនកម្មចំពោះកថាខណ្ឌ៤៥ និង កថាខណ្ឌ ៤៥ក និង ៤៥ខ ទៅថ្ងៃខាងមុខសម្រាប់ការិយបរិច្ឆេទ ប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី ១ខែ កក្កដា ឆ្នាំ ២០០៩ ។ ប្រសិនបើអង្គភាពមួយអនុវត្ត ស.គ.អ.ក ២៧ (បានធ្វើវិសោធនកម្ម ២០០៨) សម្រាប់ការិយបរិច្ឆេទមុនវិសោធនកម្ម ត្រូវបានប្រើសម្រាប់ការិយបរិច្ឆេទមុននោះ ។

៥៨ខ កថាខណ្ឌ ១ ត្រូវបានធ្វើវិសោធនកម្មដោយ *ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើម នៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ។ ការអនុវត្តត្រូវបាន

អនុញ្ញាតិ ។ ប្រសិនបើ អង្គភាពប្រើវិសោធនកម្មសម្រាប់ការិយបរិច្ឆេទមុន អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ និងប្រើសម្រាប់ការិយបរិច្ឆេទមុននោះនូវវិសោធនកម្មចំពោះកថាខណ្ឌ៣ នៃស.រ.ហ.អ.ក ៧ *ឧបករណ៍ហិរញ្ញវត្ថុៈ ការលាតត្រដាង*កថាខណ្ឌ១ នៃស.គ.អ.ក ២៨ និងកថាខណ្ឌ៤ នៃស.គ.អ.អ ៣២ *ឧបករណ៍ហិរញ្ញវត្ថុៈ ការបង្ហាញ* ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨ ។ អង្គភាពមួយត្រូវបានអនុញ្ញាត ដើម្បីប្រើវិសោធនកម្មទៅថ្ងៃខាងមុខ ។

៥៨គ [លុបចោល]

៥៨ឃ កថាខណ្ឌ ៥៨ក ត្រូវបានធ្វើវិសោធនកម្មដោយ *ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* នៅក្នុងខែឧសភា ឆ្នាំ២០១០ ។ អង្គភាពមួយត្រូវប្រើវិសោធនកម្មនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ ។ ការអនុវត្តមុនត្រូវបានអនុញ្ញាត ។ ប្រសិនបើ អង្គភាពមួយអនុវត្តវិសោធនកម្ម មុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១០ អង្គភាពត្រូវលាតត្រដាងហេតុការណ៍នោះ ។

៥៨ង ស.រ.ហ.អ.ក ៩ ត្រូវបានចេញផ្សាយនៅក្នុងខែតុលា ឆ្នាំ២០១០ បានធ្វើវិសោធនកម្មកថាខណ្ឌ ១ ៤៥-៤៥ខ និង ៥១ និងលុបចោលកថាខណ្ឌ ៥៨គ ។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទាំងនោះនៅពេលដែលអង្គភាពអនុវត្ត ស.រ.ហ.អ.ក ៩ ដូចបានចេញផ្សាយនៅក្នុងខែ តុលា ឆ្នាំ ២០១០ ។

៥៩ ស្តង់ដានេះជំនួសឱ្យ ស.គ.អ.ក ៣១ *ការរាយការណ៍ហិរញ្ញវត្ថុនៃភាគកម្ម នៅក្នុងក្រុមហ៊ុនរួមទុន* (បានកែ ប្រែនៅក្នុងឆ្នាំ២០០០)។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ